# កម្មវិធីផ្តល់ជំនួយសម្រាប់ប្រជាជនរដ្ឋម៉ាស្សាឈូសិត

## កន្លែងស្វែងរកជំនួយ ព័ត៌មាន និងការណាត់ជួបផ្នែកវេជ្ជសាស្ត្រ

ខុម៉ុនវែលម៉ាស្សាឈូសិត (Commonwealth of Massachusetts) ផ្តល់ជូននូវសេវាកម្មជាច្រើន ដើម្បីជួយប្រជាជនដែលបានប្រើអស់ ឬ ប្រហែលជាអាចប្រើអស់ការទាមទារធានារ៉ាប់រងពីភាពអត់ការងារធ្វើរបស់ពួកគេឆាប់ៗនេះ ។ ប្រជាជនអត់ការងារធ្វើ ប្រហែលអាចមានសិទ្ធិទទួលបានជំនួយដើម្បីបំពេញតម្រូវការមូលដ្ឋាន ក៏ដូចជាសេវាផ្សេងទៀតដូចជា ការថែទាំសុខភាព ការប្រឹក្សា ការងារ និងជំនួយបណ្តុះបណ្តាល និងផ្សេងទៀតជាច្រើន ។ អ្នកអាចទូរស័ព្ទមកលេខ 2-1-1 ដើម្បីសិក្សាអំពីប្រភពធនធានជាច្រើន ឬទាក់ទងភ្នាក់ងារ និងអង្គការទាំងនេះដោយផ្ទាល់ ដើម្បីសាកសួរអំពីកម្មវិធីរបស់ពួកគេ ។

Massachusetts

2-1-1™

Get Connected. Get Answers.

A Partnership of United Way and MAIRS

**2-1-1** អាចទទួលបាន 24 ម៉ោង ក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ និងបម្រើជូនដោយអ្នកផ្តល់ប្រឹក្សាដែលអាចឱ្យអ្នកទទួលបានជំនួយ ដែលអ្នកត្រូវការ ។ រាល់ការហៅទូរស័ព្ទទាំងអស់ឥត គិតថ្លៃ និងទុកជាសម្ងាត់ ។ អ្នកផ្តល់ប្រឹក្សាដែលទទួលបានការបណ្តុះបណ្តាល អាចជួយអ្នកស្ទើរតែរាល់បញ្ហាប្រឈមទាំងអស់ដូចជា ជម្រើសថែទាំកូន បណ្តុះបណ្តាលបុគ្គលិកជាថ្មី បញ្ហាសុខភាពផ្លូវចិត្ត ឬជំនួយរក ផ្ទះសម្បែង និងជួល ។

**www.mass211help.org**

Commonwealth of Massachusetts

Deval L. Patrick, Governor Timothy P. Murray, Lt. Governor

Executive Office of Labor and Workforce Development

Joanne F. Goldstein, Secretary

### ការរ៉ាប់រងថែទាំសុខភាព

**MassHealth**

ចំណាយសំរាប់ការថែទាំសុខភាព ឱ្យប្រជាជនដែលមានប្រាក់ចំណូលទាប និងមធ្យមជាក់លាក់ដែលរស់នៅរដ្ឋម៉ាស្សាឈូសិត ។

**www.mass.gov/masshealth** **800-841-2900**

### ជំនួយផ្តល់ចំណីអាហារ និងជំនួយដោយផ្ទាល់

**ជំនួយផ្តល់ចំណីអាហារ**

អត្ថប្រយោជន៏កម្មវិធីផ្តល់ជំនួយអាហារូបត្ថម្ភបន្ថែម (Supplemental Nutrition Assistance Program - SNAP) [ពីមុនត្រូវបានស្គាល់ថាជា Food Stamp] ជួយគ្រួសារដែលមានប្រាក់ចំណូលទាប ទិញចំណីអាហារូបត្ថម្ភនៅហាងលក់ គ្រឿងទេស ហាង និងឱសថស្ថានដែលមានភាពងាយស្រួលភាគច្រើនបំផុត ។

**www.mass.gov/snap** **866-950-3663**

**ជំនួយដោយផ្ទាល់ (Direct Assistance)**

**ជំនួយផ្លាស់ប្តូរឱ្យគ្រួសារដែលមានកូនក្នុងបន្ទុក (Transitional Aid to Families with Dependent Children - TAFDC)**

ជំនួយជាសាច់ប្រាក់ដល់គ្រួសារដែលមានកុមារ និងស្ត្រីមានផ្ទៃពោះនៅ 120 ថ្ងៃចុងក្រោយនៃការមានគភ៌ ដែលមានទ្រព្យ ឬប្រាក់ចំណូល តិចតួច ឬគ្មាន ។

**ជំនួយបន្ទាន់ដល់ចាស់ជរា ជនពិការ និងកុមារ (Emergency Aid to the Elderly, Disabled, and Children - EAEDC)**

ជំនួយបន្ទាន់ដល់ចាស់ជរា ជនពិការ និងកុមារ (Emergency Aid to the Elderly, Disabled, and Children - EAEDC) គឺជាកម្មវិធីផ្តល់ជំនួយដោយរដ្ឋ ដែលផ្តល់ជូននូវជំនួយជាសាច់ប្រាក់ ដល់អ្នកទាំងលាយដែលត្រូវការឱ្យមានស្ថេរភាពជីវិតរបស់ ពួកគេ ។

**ខ្សែទូរស័ព្ទផ្តល់ព័ត៌មានពីពាក្យសុំ** (សំរាប់ TAFDC និង EAEDC) ។

សំរាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ក្រសួងផ្តល់ជំនួយផ្លាស់ប្តូរ (Department of Transitional Assistance)

**www.mass.gov/dta** **800-249-2007**

**ខ្សែទូរស័ព្ទ Foodsource - Project Bread**

ដើម្បីស្វែងរកកន្លែងលក់ចំណីអាហារ និងប្រភពធនធានអាហារូបត្ថម្ភផ្សេងៗនៅក្នុងសហគមន៏របស់អ្នក

**www.projectbread.org** **800-645-8333**

### ប្រភពធនធានផ្តល់ផ្ទះសម្បែង

**មជ្ឈមណ្ឌលអប់រំអ្នកប្រើប្រាស់ផ្ទះសម្បែងធំ (Mass Housing Consumer Education Centers)**

មជ្ឈមណ្ឌលចំនួនប្រាំបួននៅទូទាំងរដ្ឋម៉ាស្សាឈូសិត ផ្តល់ជូននូវព័ត៌មានពីផ្ទះសម្បែង និងការបញ្ជូនទៅ ។ សូមភ្ជាប់ជាមួយប្រភពធនធានស្តីពីការទប់ស្កាត់ការប្តឹងរឹបអូស ជំនួយជួល និងការទំនុកបំរុងជាប្រាក់ ការស្វែងរកផ្ទះសម្បែង ផ្ទះសម្បែង ផ្លាស់ប្តូរ និងគាំទ្រសំរាប់ការគ្មានផ្ទះសម្បែង និងអ្វីៗជាច្រើនទៀត ។

**www.masshousinginfo.org** **800-224-5124**

**ក្រសួងផ្តល់ផ្ទះសម្បែង និងអភិវឌ្ឍន៏សហគមន៏ (Department of Housing and Community Development)**

សំរាប់ជំនួយផ្ទះសម្បែង ទីជម្រក និងប្រេងឥន្ទនៈ ។

| | |
|---|---|
| នាយកដ្ឋានស្ថេរភាពផ្ទះសម្បែង (Division of Housing Stabilization) | **877-418-3308** |
| ជំនួយប្រេងឥន្ទនៈ និងការធ្វើឱ្យផ្ទះទប់ទល់អាកាសធាតុបាន (Fuel Assistance and Weatherization) | **800-632-8175** |
| នាយកដ្ឋានផ្ទះសម្បែងសាធារណៈ និងជំនួយជួល (Division of Public Housing and Rental Assistance) | **617-573-1150** |

**www.mass.gov/dhcd**

**ជំនួយលើការប្តឹងរឹបអូស (Foreclosure Assistance)**

ការផ្តល់ប្រឹក្សា និងជំនួយលើការប្តឹងរឹបអូសសំរាប់ម្ចាស់ផ្ទះ

**www.mass.gov/ocabr** **888-995-4673**

### អត្ថប្រយោជន៏របស់អតីតយុទ្ធជន

**ក្រសួងសេវាអតីតយុទ្ធជន (Department of Veterans' Services)**

អត្ថប្រយោជន៏ និងប្រភពធនធានសំរាប់អតីតយុទ្ធជន និងគ្រួសាររបស់ពួកគេ ប្រហែលជាអាចទទួលបានតាមរយៈមន្ត្រីសេវាអតីតយុទ្ធជនក្នុងតំបន់របស់អ្នក ។

**www.mass.gov/veterans** **617-210-5480**

### ជំនួយគាំទ្រកុមារ (CHILD SUPPORT ASSISTANCE)

**ក្រសួងប្រាក់ចំណូល (Department of Revenue)**

សំរាប់ជំនួយចំពោះសេចក្តីបង្គាប់ឱ្យមានការគាំទ្រកុមារ ។

**www.mass.gov/cse** **800-332-2733**

### សេវាដល់ចាស់ជរា

ជួយចាស់ជរា និងគ្រួសាររបស់ពួកគេ កំណត់ពីសេវា និងឱកាស ។

**www.mass.gov/elder** **800-243-4636**

### ប្រភពធនធានតាមសហគមន៏

**សមាគមសកម្មភាពសហគមន៏រដ្ឋម៉ាស្សាឈូសិត (Massachusetts Association For Community Action - MASSCAP)**

សេវារួមមានជំនួយប្រេងឥន្ទនៈ និងការធ្វើឱ្យផ្ទះទប់ទល់អាកាសធាតុបាន ការទប់ស្កាត់ការគ្មានផ្ទះសម្បែង ជំនួយចំណីអាហារបន្ទាន់ និងការបណ្តុះបណ្តាលការងារ ។

**www.masscap.org** **617-357-6086**

# ការងារ អាជីព ការបណ្តុះបណ្តាល

## ការងារ អាជីព និងការបណ្តុះបណ្តាល

**មជ្ឈមណ្ឌលអាជីពច្រកចេញចូលតែមួយ (One Stop Career Centers)** - ជាកិច្ចខិតខំប្រឹងប្រែងសហការមួយក្នុងចំណោមភ្នាក់ងារ អាជីវកម្ម និងអង្គការមិនសំដៅប្រាក់ចំណេញក្នុងតំបន់ និងរដ្ឋ - ដែលផ្តល់ឱ្យអ្នកស្វែងរកការងារនូវតារាងព័ត៌មាន និងសេវាកម្មប្រកបដោយគុណភាពជាច្រើន និងអាចទទួលបានយ៉ាងងាយស្រួល - ដោយឥតគិតថ្លៃ។

### អ្នកស្វែងរកការងារអាច :

- ទទួលបានជំនួយស្វែងរកការងារ
- ធ្វើការជាមួយអ្នកផ្តល់ប្រឹក្សាពីអាជីពដែលមានបទពិសោធន៍
- សិក្សាអំពីយុទ្ធសាស្ត្រស្វែងរកការងារដែលរួមមាន ការសម្ភាសន៍ ការបង្កើតបណ្តាញ និងការសរសេរប្រវត្តិរូប
- ចូលរួមសិក្ខាសាលា និងការបណ្តុះបណ្តាលរយៈពេលខ្លី ដោយរួមទាំងការបណ្តុះបណ្តាលកុំព្យូទ័រថ្នាក់មូលដ្ឋានផងដែរ
- បង្កើតបណ្តាញជាមួយអ្នកស្វែងរកការងារផ្សេងទៀត
- ទទួលបានបញ្ជីការងារក្នុងតំបន់ រដ្ឋ និងប្រទេសកែប្រែចុងក្រោយបំផុត
- ទទួលបានឱកាសបណ្តុះបណ្តាល/អប់រំវិជ្ជាជីវៈ
- ទទួលបានសេវាកម្មបន្ទប់ផ្តល់ធនធានរួមមាន កុំព្យូទ័រ កាសែត សារព័ត៌មានជំនាញ បញ្ជីរាយក្រុមហ៊ុន ម៉ាស៊ីនទូរសារ និងម៉ាស៊ីនថតចម្លង ការបោះពុម្ពផ្សាយពីសកម្មភាពស្វែងរកការងារ និង អាជីព

MASSACHUSETTS ONE STOP CAREER CENTERS

**មជ្ឈមណ្ឌលអាជីពច្រកចេញចូលតែមួយ (One Stop Career Centers) មានទីតាំងនៅទូទាំងរដ្ឋ។**

ដើម្បីស្វែងរកមជ្ឈមណ្ឌលអាជីពដែលមាន ភាពងាយស្រួលបំផុត ស្របជាមួយនឹងបញ្ជីសេវាកម្មរបស់មជ្ឈមណ្ឌល ម៉ោងធ្វើការ និង ការណែនាំ សូមចូលទៅកាន់ **www.mass.gov/careercenters** ឬទូរស័ព្ទមកលេខ call **877-872-5627** ។ ដើម្បីទទួលការផ្សាយការងារចុងក្រោយបំផុត សូមចូលទៅកាន់ **www.mass.gov/jobquest** ឬទូរស័ព្ទមកលេខ **888-578-6599**

## កម្មវិធីផ្តល់ជំនួយអាហារូបត្ថមបន្ថែម (SNAP)

កម្មវិធីផ្តល់ជំនួយអាហារូបត្ថម្ភបន្ថែម (**Supplemental Nutrition Assistance Program – SNAP**) គឺជាកម្មវិធីអាហារូបត្ថម្ភមួយសម្រាប់គ្រួសារ និងបុគ្គលទាំងឡាយ ដែលបំពេញបានតាមសេចក្តីណែនាំពីប្រាក់ចំណូល និងធនធាន ជាក់លាក់។

អត្ថប្រយោជន៏របស់ SNAP ជួយគ្រួសារដែលមានចំណូលទាប ឱ្យទិញចំណីអាហារូបត្ថម្ភនៅហាងលក់ម្ហូបអាហារ ហាងដែលផ្តល់ភាពងាយស្រួល និងឱសថស្ថានភាគច្រើន បំផុត។ អ្នកទទួលបាន SNAP អាចនឹងកំពុង មានការងារធ្វើ និង នៅតែមានលក្ខណៈសម្បត្តិ ទទួលបាន SNAP ដដែល។

### SNAP Hotline

(ពីមុនត្រូវបានស្គាល់ថាជា Food Stamps)

**866-950-3663**

**www.mass.gov/snap**

Commonwealth of Massachusetts

Deval L. Patrick, Governor

Timothy P. Murray, Lt. Governor

Executive Office of Labor and Workforce Development

Joanne F. Goldstein, Secretary

និយោជិកដែលផ្តល់ឱកាសស្មើភាពគ្នា - អាចទទួលបានជំនួយ និងសេវាកម្មបន្ថែមតាមការស្នើសុំចំពោះមនុស្សពិការ